# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៧ ស.ស.រ

### សេចក្តីសម្រេច
### ស្តីពី
### ការប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ដើម្បីធ្វើជាគណៈអធិបតី ក្នុងពិធីប្រកាសចូលកាន់តំណែងថ្នាក់ដឹកនាំខេត្ត និងស្រុក នៃខេត្តកោះកុង

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញសេចក្តីសម្រេចលេខ ៦៦ សសរ. ចុះថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### ស ម្រេ ច

**ប្រការ ១ :** ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី ដើម្បីធ្វើជាគណៈអធិបតីក្នុងពិធីប្រកាសចូលកាន់តំណែងអភិបាល អភិបាលរងខេត្តកោះកុង និងអភិបាល អភិបាលរងស្រុកស្រែអំបិល នៃខេត្តកោះកុង ដោយមានឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អមដំណើរ ។

www.pheakdeylaw.com

ប្រការ ២: ក្រសួងមហាផ្ទៃមានភារកិច្ចរៀបចំកម្មវិធី និងចាត់តាំងមន្ត្រីជំនាញពាក់ព័ន្ធចូលរួមក្នុងពិធីប្រកាសចូលកាន់តំណែង ដូចបានកំណត់ក្នុងប្រការ១ ខាងលើ ។

ប្រការ ៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ សាលាខេត្តកោះកុង ឯកឧត្តម ឆៀ ឃាញ់ និងឯកឧត្តម ថ្នាំ សុខា ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រីស្តីទី

ស ខេង

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com